ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

អគ្គនាយកដ្ឋានកសិកម្ម

លេខ.....០៧០..........អ.ន.ក

# សេចក្តីប្រកាសព័ត៌មាន

កាលពីថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២០ សារព័ត៌មានវីអូឌីខ្មែរ (VOD-Khmer) និងសារព័ត៌មានមួយចំនួន បានចុះផ្សាយថា "ប្រជាកសិករមួយចំនួន (ជាសពិសេស លោក តែ សុង) នៅស្រុកស្អាង ខេត្តកណ្តាល បានត្អូញត្អែរថា បន្លែរបស់ពួកគាត់ប្រឈមនឹងការឈូសចោលក្នុងរយៈពេលប៉ុន្មានថ្ងៃខាងមុខនេះ បើសិននៅតែពុំមានទីផ្សារសម្រាប់លក់ ស្របពេលដែលកម្ពុជាកំពុងជួបបញ្ហាជំងឺកូវីដ-១៩ និងការនាំចូលបន្លែពីប្រទេសជិតខាងច្រើន"។

ឆ្លើយតបនឹងព័ត៌មានខាងលើ អគ្គនាយកដ្ឋានកសិកម្ម សូមជម្រាបជូនសាធារណជនជ្រាបថា៖

លោក តែ សុង មានមុខរបរជាអ្នកលក់សម្ភារកសិកម្ម និងបានជួលដីគេដាំសាលាដ ប្រមាណជាង១ហិកតា ដោយគាត់យល់ថា នឹងអាចទទួលបានតម្លៃល្អ ដែលបច្ចុប្បន្ន បន្លែរបស់គាត់បានប្រមូលផលលក់អស់ជាង ៥០%ហើយ។ ម្យ៉ាងទៀត ក្នុងផលិតកម្មដំណាំបន្លែនេះ គាត់មិនបានចូលរួមនៅក្នុងបណ្តុំអាជីវកម្ម ឬសហគមន៍កសិកម្ម និងមិនបានអនុវត្តតាមគោលការណ៍ស្តង់ដារបន្លែសុវត្ថិភាពណាមួយ ដែលធ្វើឱ្យបន្លែរបស់គាត់ពិបាករកទីផ្សារ។ ទន្ទឹមនឹងនេះ កសិករជាច្រើនបានដាំដុះក្នុងពេលតែមួយស្របគ្នានៅក្នុងរដូវដែលមានលក្ខណៈអំណោយផលសម្រាប់ផលិតកម្មបន្លែ និងប្រមូលផល ធ្វើឱ្យបរិមាណផលសាលាដកើនឡើងច្រើនលើសតម្រូវការទីផ្សារ ហើយស្របពេលដែលប្រទេសកម្ពុជាកំពុងជួបបញ្ហាជំងឺកូវីដ-១៩ ផង ធ្វើឱ្យតម្លៃបន្លែធ្លាក់ចុះ។ ដើម្បីជួយដោះស្រាយបញ្ហា ក្រុមហ៊ុន Tropicam បានចុះជួបលោក តែ សុង និងបានពិភាក្សាអំពីកិច្ចសន្យាផលិតកម្មបន្លែសុវត្ថិភាព និងការធានាទិញបន្លែដែលផលិតបាននៅឆ្នាំ២០២១។

អគ្គនាយកដ្ឋានកសិកម្ម សហការជាមួយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត បាននិងកំពុងអភិវឌ្ឍបន្លែសុវត្ថិភាពតាមស្តង់ដារការអនុវត្តកសិកម្មល្អ ជំរុញការចងក្រងបណ្តុំអាជីវកម្មផលិតបន្លែ និងសហការជាមួយវិស័យឯកជនដើម្បីអនុវត្តកសិកម្មតាមកិច្ចសន្យា។

អគ្គនាយកដ្ឋានកសិកម្ម សូមសំណូមពរដល់ប្រជាកសិករ ចូលរួមអនុវត្តការដាំដុះបន្លែតាមស្តង់ដារសុវត្ថិភាព ចូលរួមក្នុងបណ្តុំអាជីវកម្មផលិតបន្លែ និងប្រើប្រាស់ប្រព័ន្ធ Online "CAMAgriMarket APP" ដើម្បីងាយស្រួលក្នុងការរៀបចំផែនការផលិតកម្មតាមប្រភេទបន្លែ តាមរដូវកាលដាំដុះ និងឆ្លើយតបតាមតម្រូវការទីផ្សារ ដោយអនុវត្តកសិកម្មតាមកិច្ចសន្យាជាមួយវិស័យឯកជន ដើម្បីធានាគុណភាព សុវត្ថិភាព និងនិរន្តភាពទីផ្សារ។

ថ្ងៃចន្ទ ១៤រោច ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២០